Khmer

What is Sexual Assault and where you can get help.

# អ្វីទៅដែលហៅថាការរំលោភតាមផ្លូវភេទ ហើយតើអ្នករកជំនួយនៅកន្លែងណា?

# សេចក្តីថ្លែងអំណរគុណ

© Education Centre Against Violence:

ខែកក្កដា ឆ្នាំ១៩៩៩

ISBN: 1 876969 032

ដើម្បីទទួលយកកូនសៀវភៅនេះជាភាសាចិន ទួរគី ខ្មែរ វៀតណាម កូរ៉េ ភុនយ៉ាប៊ី/ហ៊ីនឌី អេស្ប៉ាញ អារ៉ាប់ និងអ៊ីតាលី សូមទាក់ទងជាមួយ:

For further copies of booklets in Chinese, Turkish, Khmer, Vietnamese, Korean, Punjabi/Hindi, Spanish, Italian and Arabic, contact:

ECAV
Locked Bag 7118
Parramatta BC 2150
ទូរស័ព្ទ: 61 2 9840 3737
email: ecav@wsahs.gov.au

Educational Institutions ត្រូវបានអនុញ្ញាតអោយចម្លងកូនសៀវភៅនេះទាំងមូល ឬផ្នែកខ្លះ ហើយមិនបានតម្រូវអោយបង់ថ្លៃទៅអោយអ្នកនិពន្ធ/អ្នកបោះពុម្ព ដោយយោងទៅលើការគោរពសិទ្ធិនោះឡើយ ។

Educational Institutions are permitted to copy whole or part of this work and shall not be liable for the payment of fees to the author/publisher in respect of copyright.

គំរោងការណ៍ផ្តល់ពត៌មានអំពីការរំលោភតាមផ្លូវភេទបានផ្តួចផ្តើមឡើងដោយ មជ្ឈមណ្ឌលអប់រំប្រឆាំងអំពើឃោរឃៅ ។

កូនសៀវភៅពត៌មានជាភាសាខ្មែរនេះបានកើតឡើងបន្ទាប់ពីមានការសាកសួរយោបល់ពីអស់អ្នកធ្វើការខ្មែរមួយចំនួនដែលបានដឹងយល់ពីបញ្ហាក្នុងសង្គមខ្មែរ ព្រមទាំងមានការណែនាំពីក្រុមអ្នកធ្វើការមួយក្រុមផង ។

យើងសូមថ្លែងអំណរគុណជាពិសេសដល់ក្រុមអ្នកធ្វើការមួយចំនួនដូចខាងក្រោមនេះ ដែលបានចំណាយពេលវេលាជាច្រើន ក្នុងការផ្តល់យោបល់ និងជួយណែនាំអោយកើតជាកូនសៀវភៅនេះឡើង:

១. អ្នកស្រីតេក ហ៊ាង យ៉ា អ្នកធ្វើការផ្នែកសុខុមាលភាពគ្រួសារ នៅមណ្ឌលប៊ុនសាយ ខាប្រ៉ាម៉ាតា
២. អ្នកស្រីវ៉ារី ហេង អ្នកធ្វើការផ្នែកសុខភាពខ្មែរនៅមណ្ឌលសុខភាពសហគមន៍ ខាប្រ៉ាម៉ាតា
៣. អ្នកស្រីផាន់ណា ប៉ាវ និងចន្ថា លឹម អ្នកធ្វើការប្រចាំក្រុមប្រឹក្សាសុខុមាលភាពខ្មែរ-អូស្ត្រាលី ។
៤. អ្នកស្រីសូរាធី មីស្សែរល នាយកសាលាខ្មែរ ប៊ុន្នីរីក។

កូនសៀវភៅពត៌មានជាភាសាខ្មែរនេះ ត្រូវបានរៀបរៀងឡើងដោយអ្នកស្រីតេក ហ៊ាង យ៉ា ព្រមទាំងមានសហការពីក្រុមអ្នកធ្វើការខាងលើ ។

# បញ្ជីអត្ថបទ


អ្វីទៅដែលជាអំពើរំលោភតាមផ្លូវភេទ? ........................................1

ការរំលោភកុមារតាមផ្លូវភេទ ........................................1

តើអ្នកណាខ្លះជាជនរងគ្រោះ ........................................2

ជំនឿ និងការយល់ខុសទៅលើការរំលោភតាមផ្លូវភេទ ........................................2

ការរំលោភតាមផ្លូវភេទរវាងប្ដីប្រពន្ធ ........................................3

អារម្មណ៍របស់ជនរងគ្រោះ ........................................3

អារម្មណ៍របស់បុរសរងគ្រោះ ........................................4

តើជនរងគ្រោះត្រូវប្រាប់អ្នកណា? ........................................4

សេចក្ដីត្រូវការ និងសិទ្ធិរបស់ជនរងគ្រោះ ........................................5

កិច្ចបំរើសំរាប់ជនរងគ្រោះដោយការរំលោភតាមផ្លូវភេទ ........................................5

តើកិច្ចបំរើទាំងនោះអាចផ្ដល់អ្វីខ្លះ? ........................................6

ការពិភាក្សាផ្ដល់យោបល់ ........................................6

របៀបប្រើអ្នកបកប្រែភាសា ........................................7

សន្ទានុក្រមពាក្យអង់គ្លេស-ខ្មែរ ........................................8

កិច្ចបំរើខ្លះៗដែលមានបុគ្គលិកខ្មែរ ........................................10

អាស័យដ្ឋានកិច្ចបំរើផ្ដល់ជំនួយលើការរំលោភតាមផ្លូវភេទ ........................................11

# អ្វីទៅដែលជាអំពើរំលោភតាមផ្លូវភេទ?

What is sexual assault?

ការរំលោភតាមផ្លូវភេទ គឺជាអំពីឧក្រិដ្ឋមួយ ។ វាគឺជាការបំពានបំពារទាំងអំណាច បង្ខំអោយជនណាម្នាក់រួមភេទជាមួយខ្លួន នៅពេលណាមួយ នៅកន្លែងណាមួយ ទោះបីថាក្នុងផ្ទះក័ដោយ ។

ការរំលោភលើផ្លូវភេទ អាចរាប់បញ្ចូលទាំង:

- ❖ សំដីលួកលាន់ លែបខាយខាងផ្លូវភេទ ។
- ❖ ការប៉ុនប៉ងរំលោភ ។
- ❖ ការស្ទាបលូកលាន់ដោយចេតនា ។
- ❖ ការបង្ខំអោយមើលភាពយន្តអាសអាភាស ។
- ❖ អោយស្តាប់ពាក្យកំប្លែងចំអេសចំអាស ។

ស្ត្រីភាគច្រើន (៨៥%) ត្រូវបានរំលោភដោយមនុស្សដែលខ្លួនធ្លាប់ស្គាល់ តាមការប្រើកម្លាំង អំណាច ចាប់បង្ខំ ក្នុងលក្ខណៈដែលស្ត្រីទាំងនោះគ្មានលទ្ធភាពនឹងទប់ទល់លើការរំលោភបាន ។ ដូចនេះ ស្ត្រីរងគ្រោះនោះតែងតែបន្ទោសខ្លួនឯង ទោះបីជាកំហុសរបស់ជនកំហូចក័ដោយ ។

ការរំលោភលើផ្លូវភេទកើតមានជាញឹកញាប់លើស្ត្រី និងកុមារ ក័ប៉ុន្តែមានលើមនុស្សប្រុសដែរ ។ ការរំលោភលើផ្លូវភេទ កើតមានជាញឹកញាប់នៅក្នុងរង្វង់គ្រួសារ ។ ភាគច្រើនជនទុរយសទាំងនោះគឺជាអ្នកដែលជនរងគ្រោះស្គាល់ច្បាស់ ។

# ការរំលោភកុមារតាមផ្លូវភេទ

Sexual assault of children

- ❖ ការរំលោភកុមារតាមផ្លូវភេទ ជាបទឧក្រិដ្ឋ ។
- ❖ វាអាចកើតមានដោយមនុស្សចាស់ ឬមនុស្សធំជាងប្រើកម្លាំង ឬអំណាចលើក្មេង ឬដោយការបោកបញ្ឆោតក្មេងអោយធ្វើសកម្មភាពណាមួយ តាមចំណង់តណ្ហារបស់ខ្លួន ។

**បើអ្នកត្រូវបានគេរំលោភ នោះមិនមែនជាកំហុសអ្នកទេ**

# តើអ្នកណាខ្លះជាជនរងគ្រោះ?

Who are the victims

ការរំលោភតាមផ្លូវភេទ អាចកើតមានលើជនគ្រប់វណ្ណៈ សញ្ជាតិ មិនថាចាស់ ឬក្មេង ។

- ❖ ៨៥%នៃជនរងគ្រោះជាស្ត្រី និង១៥%ជាបុរស ។
- ❖ ៨៥%នៃកុមាររងគ្រោះត្រូវបានរំលោភដោយសមាជិកគ្រួសារ សាច់ញាតិ ឬអ្នកដែលគេស្គាល់ ហើយ៩៧%នៃជនទាំងនោះជាមនុស្សប្រុស ។
- ❖ ជនអាក្រក់ទាំងនោះ ច្រើនជាមនុស្សដែលធ្លាប់ស្គាល់ទុកចិត្តច្បាស់ជាងមនុស្សចំឡែក ។*

* តាមសេចក្ដីរាយការណ៍ប្រចាំឆ្នាំ១៩៩៦/៩៧ ក្រសួងរដ្ឋាភិបាលញូវសៅវែល

# ជំនឿ និងការយល់ខុសនៅលើការរំលោភតាមផ្លូវភេទ

Myths and misconception about sexual assault

មានមតិមួយចំនួនក្នុងសង្គមយើងតែងតែដាក់កំហុសទៅលើជនរងគ្រោះ ថាការរំលោភអាចកើតឡើងទៅបាន យោងទៅតាមហេតុការណ៍ដូចខាងក្រោមនេះ:

- ❖ ជនរងគ្រោះឥតមានការប្រុងប្រយ័ត្នដោយធ្វើដំណើរម្នាក់ឯងពេលយប់ ឬសេពគប់ជាមួយជនចំឡែក ។
- ❖ ជនរងគ្រោះបង្កើតអោយមានភាពស្រើបស្រាលដោយការតែងខ្លួន ពាក់អាវរៀលបញ្ចេញសាច់ ឬលែបខាយអោយគេ ។
- ❖ ជនរងគ្រោះមិនបានតដៃអោយបានខ្លាំង ឬមិនបានស្រែកអោយគេជួយផង ។

ដូច្នេះសមាជិកគ្រួសារ ដូចជាឪពុកម្ដាយ បងប្អូន ស្វាមី ឬគូកំណាន់ គួរយល់ពីហេតុការណ៍ដែលបានកើតឡើងដោយសន្ដោសប្រណី គាំទ្រទាំងផ្លូវកាយ និងផ្លូវចិត្តដល់ជនរងគ្រោះ ។

# ការរំលោភតាមផ្លូវភេទរវាងប្តីប្រពន្ធ

Sexual assault in marriage

ការចាប់បង្ខំ រួមដំណេករវាងប្តីប្រពន្ធដោយខ្វះការយល់ព្រមពីគ្នា ចាត់ទុកជាការរំលោភ ។ នៅប្រទេសអូស្ត្រាលី ប្តីដែលរំលោភប្រពន្ធឯង ជាអំពើមួយខុសច្បាប់ ។ ស្ថិតិបានបង្ហាញថា យ៉ាងហោចណាស់មានស្ត្រីម្នាក់ ក្នុងចំណោម៧នាក់បានត្រូវរំលោភដោយប្តីរបស់ខ្លួន ។

# អារម្មណ៍របស់ជនរងគ្រោះ

Victims feelings

បន្ទាប់ពីពេលកើតហេតុមក ជនរងគ្រោះតែងតែមានអារម្មណ៍ប្លែកៗពីគ្នា ដូចជា:

- ❖ វាធ្វើអោយខ្ញុំចង់តែយំរហូត ដោយគ្មានហេតុផល ។
- ❖ ខ្ញុំស្លុតពេក – យំក៏មិនចេញ ។
- ❖ ខ្ញុំចេះតែខ្លាចគ្រប់សព្វទាំងអស់: តើខ្ញុំមានផ្ទៃពោះក៏មិនដឹង? ខ្ញុំខ្លាចគេដឹងថាខ្ញុំមានគេរំលោភ ខ្ញុំចេះតែគិតមិនឈប់ ខ្ញុំយល់សប្តិអាក្រក់ជានិច្ច ។
- ❖ តើគេមើលមកខ្ញុំថាជាមនុស្សបែបណាដែរ ? ទេខ្ញុំមិនអាចប្រាប់អ្នកណាបានទេ ។
- ❖ ខ្ញុំយល់ថាមកពីខ្ញុំបានជារឿងនេះកើតមានឡើង ។
- ❖ ខ្ញុំអស់ទឹកចិត្ត និងអស់សង្ឃឹម ។ តើអោយខ្ញុំធ្វើយ៉ាងម្តេចតទៅមុខទៀត ។
- ❖ ខ្ញុំចង់សងសឹកវាវិញ ពីព្រោះវាបានធ្វើបាបខ្ញុំ ។
- ❖ ខ្ញុំព្រួយចិត្តណាស់ គេងមិនបាន ញុំាមិនបាន ពិបាកដកដង្ហើម ឈឺពោះ យល់សប្តិអាក្រក់ ។
- ❖ ហេតុដូចម្តេចបានជាគេធ្វើយ៉ាងនេះមកលើខ្ញុំ?

# អារម្មណ៍របស់បុរសរងគ្រោះ

## Feelings for men who have been sexually assaulted

បុរសដែលបានត្រូវគេរំលោភ ក៏មានអារម្មណ៍ខ្មាស់អៀន និងទន់ខ្សោយដូចស្ត្រីរងគ្រោះដែរ ។

ជាបន្ថែម គេអាចមានអារម្មណ៍ផ្សេងទៀតដូចជា:

- ❖ ច្របូកច្របល់ខាងផ្លូវភេទ ព្រោះខ្លាចមនុស្សក្នុងសង្គមយល់ច្រឡំថាខ្លួនគេជាមនុស្សប្រុសស្រឡាញ់ប្រុស ។
- ❖ ខ្លាចគេមិនជឿនូវហេតុការណ៍ ដែលបានកើតឡើង ។

# តើជនរងគ្រោះត្រូវប្រាប់អ្នកណា?

## Who do the victimised tell?

សង្គមខ្មែរយើងបានផ្តល់សេរីភាពទៅលើបុរសច្រើនជាងស្ត្រីក្នុងផ្នែកកាមតណ្ហា ហើយថែមទាំងទាមទារស្ត្រីអោយថែរក្សាព្រហ្មចារី និងភាពស្មោះត្រង់ជានិច្ច ។

នេះគឺជាកត្តាមួយដែលធ្វើអោយស្ត្រីរងគ្រោះ តែងតែទទួលនូវវិប្បដិសារីពីការបាត់បង់កិត្តិយស ។ ជាការពិបាកណាស់ចំពោះស្ត្រីរងគ្រោះ ក្នុងការប្រាប់ជនណាម្នាក់ថាខ្លួនបានត្រូវគេរំលោភ ។ នាងខ្លាចក្រែងគេដឹង ឬអាចនាំអោយអាម៉ាសមុខដល់ក្រុមគ្រួសារ និងខ្លួនឯង ។

ស្ថិតិបានបង្ហាញថាប្រហែល២៥% ឬមួយភាគបួននៃការរំលោភលើផ្លូវភេទប៉ុណ្ណោះ ត្រូវបានគេរាយការណ៍ដល់ប៉ូលីស ។

# សេចក្តីត្រូវការ និងសិទ្ធិរបស់ជនរងគ្រោះ

The needs and rights of victims

យើងត្រូវតែចាំជាក់ថា ការរំលោភខាងផ្លូវភេទមិនមែនជាកំហុសរបស់ជនរងគ្រោះទេ ។

ដូច្នេះជនរងគ្រោះត្រូវការអោយអ្នក:

- ❖ ជឿលើរឿងរ៉ាវ ដែលបានកើតមានឡើង ។
- ❖ ស្តាប់ដោយយកចិត្តទុកដាក់ ។
- ❖ ព្រមទទួលស្គាល់ និងជួយលាក់ការណ៍ ។
- ❖ យកចិត្តទុកដាក់នូវសុខទុក្ខរបស់គេ ។
- ❖ ជួយលើកទឹកចិត្ត និងគាំទ្រដោយស្មោះ ។

ជាមួយគ្នានេះដែរ ជនរងគ្រោះក៏មានសិទ្ធិ:

- ❖ អោយគេការពារ និងគោរព ។
- ❖ ទទួលយកយោបល់ និងមតិផ្សេងៗ ។
- ❖ ធ្វើការសំរេចចិត្តដោយខ្លួនឯង ។

# កិច្ចបំរើសំរាប់ជនរងគ្រោះដោយការរំលោភតាមផ្លូវភេទ

Services for victims of sexual assault

កិច្ចបំរើសំរាប់ជនរងគ្រោះដោយការរំលោភតាមផ្លូវភេទ មាននៅគ្រប់មណ្ឌលសុខភាពតំបន់ និងមន្ទីរពេទ្យទាំងអស់ ក្នុងរដ្ឋញូវសៅវែល ។ កិច្ចបំរើទាំងនោះជាកិច្ចបំរើដោយឥតគិតថ្លៃ រក្សាការសំងាត់ ហើយប្រចាំការ២៤ម៉ោងផង ។

# តើកិច្ចបំរើទាំងនោះអាចផ្តល់អ្វីខ្លះ?

What can the services provide

អ្នកឯកទេសខាងការពិភាក្សាផ្តល់យោបល់អាចផ្តល់ជូន:

- ការពិភាក្សាផ្តល់យោបល់ដល់ជនរងគ្រោះ បន្ទាប់ពីបានត្រូវគេរំលោភភ្លាមៗ និងតទៅថ្ងៃមុខទៀត ។
- ជំនួយ និងការគាំទ្រទាក់ទងដល់បញ្ហាសន្តិសុខរបស់អ្នក ដូចជាការជួយរកជម្រកបណ្តោះអាសន្នជាដើម ។
- ពត៌មានទាក់ទងដល់ការរាយការណ៍ទៅប៉ូលីស និងការប្តឹងទៅតុលាការ ។
- ការគាំទ្រ និងពត៌មានដល់គូស្រករ សមាជិកគ្រួសារ និងមិត្តសំឡាញ់ ។
- ជួយរៀបចំសំណុំរឿង និងគាំទ្រពេលឡើងតុលាការ ។
- ជំនួយក្នុងការដាក់ពាក្យទាមទារយកជម្ងឺចិត្ត ។
- ការពិនិត្យ និងការព្យាបាលរោគ ។
- ការធ្វើតេស្ត និងតាមដានព្យាបាលជម្ងឺកាមរោគផងដែរ ។

**កិច្ចបំរើផ្នែកការពារកុមារ និងគ្រួសារពេលមានអាសន្ន មានប្រចាំការ២៤ម៉ោង តាមទូរស័ព្ទលេខ 13 21 11 ។**

# ការពិភាក្សាផ្តល់យោបល់

Counselling

ការពិភាក្សាផ្តល់យោបល់គឺជាឱកាសមួយសំរាប់ផ្តល់អោយអ្នកពិភាក្សាយល់អំពីអារម្មណ៍របស់អ្នក ហើយថែមទាំងបានជួយគាំទ្រទៀតផង ។

ការពិភាក្សារកយោបល់មិនមែនជាឱកាសសំរាប់អោយគេវិនិច្ឆ័យ ឬអោយឱវាទដល់អ្នកទាំងស្រុងទេ ។ គឺជាឱកាសសំរាប់ផ្តល់ការគាំទ្រដល់អ្នក ទៅតាមសេចក្តីសំរេចចិត្តណាមួយដែលអ្នកត្រូវការ ។

# អ្នកអាចត្រូវការពេលវេលាច្រើន ឬតិចទៅតាមសេចក្ដីត្រូវការរបស់អ្នក ។

# សំរាប់អ្នកមិនចេះភាសាអង់គ្លេស – របៀបប្រើអ្នកបកប្រែភាសា

## Process to use interpreter

សំរាប់អ្នកដែលមិនចេះភាសាអង់គ្លេស អ្នកអាចទូរស័ព្ទរកអ្នកបកប្រែភាសាខ្មែរ ដោយទូរស័ព្ទលេខ **131 450** ។

- ❖ បន្ទាប់ពីរវៃចូលហើយ ចូរនិយាយថា "ខ្មែរ ភ្លីស" ។
- ❖ ហើយកុំដាក់ទូរស័ព្ទចុះ – នៅរង់ចាំរហូតដល់មានខ្មែរឆ្លើយ ។
- ❖ ចូរនិយាយប្រាប់អ្នកបកប្រែភាសា ថាអ្នកចង់ជួបខាងផ្នែក "ការរំលោភតាមផ្លូវភេទ " ។
- ❖ បន្ទាប់មកអ្នកអាចនិយាយពីបញ្ហាអ្នកជាមួយគេ តាមរយៈអ្នកបកប្រែភាសាបាន ។

កិច្ចបំរើនេះធ្វើការ២៤ម៉ោងក្នុងមួយថ្ងៃ រៀងរាល់ថ្ងៃ ។ បើអ្នកត្រូវការអញ្ជើញទៅដល់ការិយាល័យនៃមណ្ឌលសុខភាពខាងផ្លូវភេទតាមតំបន់នោះ អ្នកអាចសួររកអ្នកបកប្រែភាសាបាន ។

កិច្ចបំរើនេះមានជូនដោយឥតគិតថ្លៃ និងរក្សាការសំងាត់ផង ។

# សទ្ទានុក្រមពាក្យអង់គ្លេស-ខ្មែរ សំខាន់ៗដែលប្រើក្នុងកូនសៀវភៅនេះ

## Khmer Glossary

**AVO ឬ Apprehended Violence Order** (ដីកាបញ្ឈប់មិនអោយមានអំពើឃោរឃៅ)

នេះគឺជាបញ្ជាចេញពីតុលាការ សំរាប់ការពារជនរងគ្រោះ ។ តាមធម្មតាដីកានេះមានចែងថា ជនណាមួយមិនអាចរំលោភ គំរាមកំហែង រំខាន ដេរដៀមដាម ឃ្លាំមើល ឬបំភិតបំភ័យដល់អ្នកណាបានទេ ហើយថែមទាំងហាមមិនអោយជននោះទៅក្បែរផ្ទះ ឬកន្លែងធ្វើការរបស់អ្នកនោះទៀតផង ។ ក្នុងករណីខ្លះ ប៉ូលីសអាចជួយសុំអោយជនរងគ្រោះ ក្នុងកាលៈទេសៈខ្លះ ដូចជាអំពើឃោរឃៅក្នុងគ្រួសារជាដើម ។

**Counselling** (ការពិភាក្សាផ្តល់យោបល់)

ការពិភាក្សាផ្តល់យោបល់ដល់ជនរងគ្រោះ តែងធ្វើឡើងដោយអ្នកមានវិជ្ជាជីវៈខាងផ្នែកចិត្តសាស្រ្តសំរាប់ជួយជនរងគ្រោះ ដើម្បីសំរាលវិបត្តិខាងផ្នែកផ្លូវចិត្ត និងសតិអារម្មណ៍ ។

**Child Sexual Assault** (ការរំលោភលើកុមារតាមផ្លូវភេទ)

គេចាត់ទុកជាការរំលោភលើកុមារតាមផ្លូវភេទ នូវរាល់អំពើអាសអាភាសផ្សេងៗ ដែលមនុស្សធំធ្វើទៅលើក្មេង ដូចជាៈ ការបង្ហាញបញ្ចេញកេរ្តិ៍ភេទ ការស្ទាបអង្អែលកេរ្តិ៍ភេទ ការធ្វើអោយមានសំរើបដោយដៃ ការរួមភេទតាមមាត់ ការស៊កម្រាមដៃ លិង្គ ឬរបស់អ្វីមួយទៅក្នុងយោនី ឬរន្ធគូថកុមារ ។

**Incest** (ស្មន្ទការ)

សំដៅលើការរួមរក្សមេត្រីរវាងជនពីរនាក់ ដែលមានជាប់សាច់ឈាមជិតគ្នា ដូចជា ឪពុក និងកូន ឬបងប្អូនបង្កើតជាដើម ។

**Rape** (ការចាប់រំលោភ)

ការចាប់បង្ខំរួមភេទលើមនុស្សម្នាក់ទៀតទាំងកម្លាំង ក្នុងគោលបំណងធ្វើអោយអ្នករងគ្រោះចុះញ៉មអំណាចរបស់ខ្លួន ។

**Sexual Abuse** (ការរំលោភបំពានតាមផ្លូវភេទ)

គឺជាពាក្យគេប្រើជាទូទៅ សំដៅទៅលើការរំលោភតាមផ្លូវភេទ ដូចជាពាក្យ **sexual assault** ដែរ ។ តែមានន័យសំដៅទៅលើអំពើរំលោភដែលកើតមានច្រើនលើកច្រើនសារ អស់រយៈពេលយូរ ។

**Sexual Assault** (ការរំលោភតាមផ្លូវភេទ)

នេះគឺជាអំពើឧក្រិដ្ឋរាប់បញ្ចូលតាំងពីការប៉ះពាល់តាមផ្លូវភេទដោយបង្ខំ ឬគ្មានការយល់ព្រមពីអ្នកម្នាក់ទៀត ជាដើម ។

**Sexual Assault in Marriage** (ការរំលោភតាមផ្លូវភេទរវាងប្តីប្រពន្ធ)
តាមច្បាប់ បើប្តីបង្ខំរួមរក្សជាមួយប្រពន្ធខ្លួនដោយគ្មានការយល់ព្រម ហើយប្តីនោះបានដឹងប្រាកដថា ប្រពន្ធនោះមិនព្រមទេ ប្តីនោះអាចជាប់ចោទតាមមាត្រាទី៦១១ នៃច្បាប់ឧក្រិដ្ឋកម្ម Crime Act ។

**Sexual Relations** (ការរួមសង្វាសនៅក្នុងទំនាក់ទំនង)
ការរួមសង្វាសតាមច្បាប់រៀបអាពាហ៍ពិពាហ៍តែម្យ៉ាងគត់ មិនបានផ្តល់សិទ្ធិដល់ស្វាមី ឬភរិយាក្នុង ការរួមសង្វាសជាមួយគ្នានោះទេ ។ តែបើមានហេតុការណ៍ដូចនេះកើតឡើង បុរសជាស្វាមី ឬស្ត្រីជា ភរិយា អាចមានទោសតាមក៏រិតច្បាប់ស្តីអំពីការរំលោភតាមផ្លូវភេទ ទោះបីជាគេប្រព្រឹត្តទៅលើប្តី ឬប្រពន្ធរបស់ខ្លួនក៏ដោយ ។

**Sexual Harassment** (ការលួកលាន់ខាងផ្លូវភេទ)
មានរាប់បញ្ចូលទាំងសំដីលែបខាយ និងអាកប្បកិរិយាលូកលាន់ដាក់អ្នកណាមួយ ជាពិសេសនៅ កន្លែងធ្វើការ ដោយគ្មានអ្នកណាហៅរក ឬលេងតបមកវិញ ។ ការលូកលាន់ខាងផ្លូវភេទរាប់តាំងពី អាកប្បកិរិយា ដូចការដៀងកន្ទុយភ្នែក ការតាំងរូបអាសអាភាស ការធ្វើសញ្ញាខិល ការប៉ះពាល់គេ ដូចជាការក្តិច ទះស្មា ឱប ដើរប្រកិតប៉ះខ្លួនគេជាដើម ។

**Victims Compensation** (ការសងជម្ងឺចិត្តដល់ជនរងគ្រោះ)
បើអ្នកបានត្រូវគេរំលោភ អ្នកអាចសុំប្រាក់សងជម្ងឺចិត្តពីរដ្ឋ តាមរយៈសាលាក្តីសំរាប់សងជម្ងឺចិត្តដល់ ជនរងគ្រោះ ។

# កិច្ចបំរើខ្លះដែលមានបុគ្គលិកខ្មែរ

Services provided by the Khmer staff

- **Khmer Community of NSW** (សហគមន៍ខ្មែរ នៃរដ្ឋញូវសៅវែល)
  ទូរស័ព្ទលេខ 9823 3479

- **Burnside Cabramatta Centre** (មណ្ឌលប៊ឺនសាយ ខាប្រ៉ាម៉ាតា)
  ទូរស័ព្ទលេខ 9728 4411

- **Fairfield Community Health Centre** (មណ្ឌលសុខភាពសហគមន៍ ហ្វែរហ្វៀល)
  ទូរស័ព្ទលេខ 9794 1700

  **Cabramatta Community Health Centre**
  ទូរស័ព្ទលេខ 8717 4000

- **STARTTS** (ស្តាត)
  ទូរស័ព្ទលេខ 9794 1900

- **Department of Community Services - Fairfield** (ក្រសួងកិច្ចការសហគមន៍ ហ្វែរហ្វៀល)
  ទូរស័ព្ទលេខ 9728 1911

- **Khmer Obstetric Worker** (ឆ្មបខ្មែរ)
  ទូរស័ព្ទលេខ 9616 8217

- **Cabramatta Police** (ប៉ូលិស ខាប្រ៉ាម៉ាតា)
  ទូរស័ព្ទលេខ 9725 8906

  **Green Valley Police**
  ទូរស័ព្ទលេខ 9607 1799

- **Lotus House** (ជំរកសំរាប់យុវនារី)
  ទីស្នាក់អាស្រ័យក្នុងរយៈពេលមធ្យមសំរាប់ស្ត្រីវ័យក្មេងដែលមកពីវប្បធម៌ឥណ្ឌូចិន (អាយុ១៤-១៨ឆ្នាំ)
  ទូរស័ព្ទលេខ 9727 0836

- **Mimosa Home** (ជំរកសំរាប់ស្ត្រី) ទីជំរកសំរាប់ស្ត្រីឥណ្ឌូចិន (អំពើរហឹង្សាតាមផ្ទះ)
  ទូរស័ព្ទលេខ 1800 656 463

# អាស័យដ្ឋានកិច្ចបំរើផ្តល់ជំនួយការរំលោភតាមផ្លូវភេទ នៅរដ្ឋញូវសៅវែល

NSW Sexual Assault Services

These phone numbers are current as at October 2001.

**Albury**
**(02) 6058 1843**
(02) 6058 4642 (ក្រោយម៉ោងធ្វើការ)

**Armidale**
**(02) 6776 4738**
(02) 6776 4622 (ក្រោយម៉ោងធ្វើការ)

**Bankstown**
**(02) 9793 7144**
(02) 9828 3000 (ក្រោយម៉ោងធ្វើការ)

**Bathurst**
**(02) 6331 5533**
(02) 6339 5311 (ក្រោយម៉ោងធ្វើការ)

**Bega**
**(02) 6492 4416** (ធ្វើការ២៤ម៉ោង)

**Blacktown/Mt Druitt**
**(02) 9881 8700**
(02) 9845 5555 (ក្រោយម៉ោងធ្វើការ)
(02) 9845 0000 (សំរាប់តែកុមារទេ)

**Bourke**
**(02) 6870 8899**
(02) 6870 8888 (ក្រោយម៉ោងធ្វើការ)

**Bowral**
**(02) 4861 8000**
(02) 4861 0200 (ក្រោយម៉ោងធ្វើការ)

**Broken Hill**
**(08) 8080 1556**
(08) 8080 1333 (ក្រោយម៉ោងធ្វើការ)

**Camperdown (Royal Prince Alfred Hospital)**
**(02) 9515 3680**
(02) 9515 6111 (ក្រោយម៉ោងធ្វើការ)

**Coffs Harbour**
**(02) 6659 1424**
(02) 6659 1599 (ក្រោយម៉ោងធ្វើការ)

**Condoblin**
**(02) 6895 2600**
(02) 6393 3000 (ក្រោយម៉ោងធ្វើការ)

**Cooma**
**(02) 6455 3201**
(02) 6455 3222 (ក្រោយម៉ោងធ្វើការ)

**Coonabarabran**
**(02) 6842 6404**
(02) 6885 8632 (ក្រោយម៉ោងធ្វើការ)

**Cowra**
**(02) 6340 2356**
(02) 6393 3000 (ក្រោយម៉ោងធ្វើការ)

**Deniliquin**
**(03) 5881 9690**
(02) 6058 4642 (ក្រោយម៉ោងធ្វើការ)

**Dubbo**
**(02) 6885 8999**
(02) 6885 8632/3 (ក្រោយម៉ោងធ្វើការ)

**East Maitland/Lower Hunter**
visiting Singleton, Dungog, Cessnock
**(02) 4933 4422**
(02) 4921 3888 (ក្រោយម៉ោងធ្វើការ)

**Glen Innes**
**(02) 6730 2166**
(02) 6730 2000 (ក្រោយម៉ោងធ្វើការ)

**Gosford/Wyong**
**(02) 4320 3175**
(02) 4320 2111 (ក្រោយម៉ោងធ្វើការ)

**Goulburn**
**(02) 4827 3913**
(02) 4827 3111 (ក្រោយម៉ោងធ្វើការ)

**Grafton**
**(02) 6640 2402**
(02) 6640 2222 (ក្រោយម៉ោងធ្វើការ)

**Griffith**
**(02) 6962 3900**
1800 800 944 (ក្រោយម៉ោងធ្វើការ)

**Gunnedah**
**(02) 6740 2888** (ធ្វើការ២៤ម៉ោង)

**Inverell**
**(02) 6728 8411**
(02) 6728 8300 (ក្រោយម៉ោងធ្វើការ)

**Kempsey**
**(02) 6562 6066**
(02) 6562 6155 (ក្រោយម៉ោងធ្វើការ)

**Kogarah (St George Hospital)**
**(02) 9350 2494**
(02) 9350 1111 (ក្រោយម៉ោងធ្វើការ)

**Lightning Ridge**
**(02) 6829 1022**
(02) 6829 1022 (ក្រោយម៉ោងធ្វើការ)

**Lismore** - visiting Byron Bay and Ballina
**(02) 6620 2970**
(02) 6621 8000 (ក្រោយម៉ោងធ្វើការ)

**Lithgow**
**(02) 6350 2750**
(02) 6339 5311 (ក្រោយម៉ោងធ្វើការ)

**Liverpool**
**(02) 9828 4844**
(02) 9828 3000 (ក្រោយម៉ោងធ្វើការ)

**Mildura/Swan Hill**
**(03) 5025 5400**
(03) 5025 5400 (ក្រោយម៉ោងធ្វើការ)

**Moree**
**(02) 6757 3632**
(02) 6757 3777 (ក្រោយម៉ោងធ្វើការ)

**Moruya**
**(02) 4474 2149**
(02) 6492 4416 (ក្រោយម៉ោងធ្វើការ)

**Muswellbrook/Upper Hunter**
visiting Denman, Scone, Merriwa, Murrundi
**(02) 6542 2050**
(02) 4921 3888 (ក្រោយម៉ោងធ្វើការ)

**Narrabri**
**(02) 6799 5100**
(02) 6799 5066 (ក្រោយម៉ោងធ្វើការ)

**Newcastle-Wallsend**
visiting Toronto, Raymond Terrace, Newcastle
**(02) 4924 6333**
(02) 4921 3888 (ក្រោយម៉ោងធ្វើការ)

**Nowra**
**(02) 4423 9211** (ធ្វើការ២៤ម៉ោង)

**Orange**
**(02) 6393 3304**
(02) 6393 3000 (ក្រោយម៉ោងធ្វើការ)

**Parkes**
**(02) 6862 1866**
(02) 6393 0000 (ក្រោយម៉ោងធ្វើការ)

**Port Macquarie**
**(02) 6588 2882**
(02) 6581 2000 (ក្រោយម៉ោងធ្វើការ)

**Queanbeyean**
**(02) 6298 9233**
(02) 6298 9211 (ក្រោយម៉ោងធ្វើការ)

**Randwick (Sydney Children's Hospital)**
Child Protection Team (សំរាប់តែកុមារទេ)
**(02) 9382 1412**
(02) 9382 1111 (ក្រោយម៉ោងធ្វើការ)

**Rosemeadow**
**(02) 4633 4100**
(02) 9828 3000 (ក្រោយម៉ោងធ្វើការ)

**St Leonards (Royal North Shore Hospital)**
Child Protection Unit (សំរាប់តែកុមារទេ)
**(02) 9926 6060**
(02) 9926 7111 (ក្រោយម៉ោងធ្វើការ)

**Adults 16 years and over**
**(02) 9926 7580**
(02) 9926 7111 (ក្រោយម៉ោងធ្វើការ)

**Tamworth**
**(02) 6766 2555**
(02) 6766 1722 (ក្រោយម៉ោងធ្វើការ)

**Taree**
**(02) 6592 9315**
(02) 6592 9111 (ក្រោយម៉ោងធ្វើការ)

**Tumut**
**(02) 6947 1811**
(02) 6938 6666 (ក្រោយម៉ោងធ្វើការ)

**Tweed Heads**
**(07) 5506 7540**
(07) 5506 7416 (ក្រោយម៉ោងធ្វើការ)

**Wagga Wagga**
**(02) 6938 6411**
(02) 6938 6666 (ក្រោយម៉ោងធ្វើការ)

**Wentworth**
Blue Mountains/Penrith/Hawkesbury
**(02) 4734 2512**
(02) 4734 2000 (ក្រោយម៉ោងធ្វើការ)

**Westmead (Children's Hospital)**
Child Protection Unit (សំរាប់តែកុមារទេ)
**(02) 9845 2434**
(02) 9845 0000 (ក្រោយម៉ោងធ្វើការ)

**Westmead (16 years and over)**
**(02) 9845 7940**
(02) 9845 5555 (ក្រោយម៉ោងធ្វើការ)

**Wollondilly**
**(02) 4683 6000**
(02) 9828 3000 (ក្រោយម៉ោងធ្វើការ)

**Wollongong**
**(02) 4222 5408**
(02) 4222 5000 (ក្រោយម៉ោងធ្វើការ)

**Young**
**(02) 6382 1522**
(02) 6382 1222 (ក្រោយម៉ោងធ្វើការ)

**NSW Rape Crisis Centre**
**(02) 9819 6565**
NSW Country **1800 42 4017**
TTY (02) 9181 4349